រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

005KH01A-01

ការផ្សព្វផ្សាយដំណឹងល្អ ប្រកបដោយប្រសិទ្ធិភាព



កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៥

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ក្រុមជំនុំរីកចំរើនឡើងបាន នៅពេលដែល យើងទាំងអស់គ្នាផ្សព្វផ្សាយដំណឹងល្អ

យើងទទួលស្គាល់អំណាចខ្ពស់បំផុតរបស់ព្រះយេស៊ូគ្រីស្ត លើក្រុមជំនុំជាព្រះសហគមន៍របស់ព្រះអង្គ ។ បើក្រុមជំនុំមួយប្រតិបត្តិតាមព្រះអម្ចាស់ ក្រុមជំនុំនោះនឹងរីកចំរើន ហើយកើនចំនួនបន្ត។ ក្រុមជំនុំប្រៀបដូចជារុក្ខជាតិ គឺថាក្រុមជំនុំមានសមត្ថភាពបង្កើនចំនួនទៅតាមពូជរបស់ខ្លួន (ម៉ាកុស ៤:២៦-២៩) ។ ដើម្បីឱ្យក្រុមជំនុំមូលដ្ឋានមួយរីកចំរើនឡើងបាន យើងត្រូវបន្តផ្សព្វផ្សាយដំណឹងល្អរបស់ព្រះយេស៊ូ ។ សូមកុំធុញទ្រាន់ក្នុងការផ្សព្វផ្សាយដំណឹងល្អឱ្យសោះ ។ យើងនឹងប្រមូលផលបានយ៉ាងឆាប់ ដោយសារព្រះជាម្ចាស់ប្រទានពរដល់យើង ។

☐ ជួយពួកអ្នកជឿថ្មីទាំងនោះ អោយឆាប់ចេះនាំមិត្តភក្តិ និងសាច់ញាតិរបស់ពួកគេផ្ទាល់ មកថ្វាយខ្លួនទៅព្រះជាម្ចាស់តាមរបៀបដូចគ្នានេះដែរ ។

☐ ទន្ទេញ កិច្ចការ ១៦:៣១ ។

កំណត់ចំណាំ :

កិច្ចការដែលត្រូវអនុវត្ត

សូមគូសសញ្ញា «✓» ក្នុងប្រអប់ «□» នេះ នៅពេលដែលអ្នកអនុវត្តកិច្ចការទាំងនេះ ។

□ ទូលសូមអោយព្រះជាម្ចាស់ជួយអ្នកជឿថ្មី អោយអាចផ្សព្វផ្សាយ ដំណឹងល្អប្រាប់សាច់ញាតិ និង មិត្តភក្តិផ្ទាល់របស់ពួកគេបាន ។

□ ផ្សព្វផ្សាយដំណឹងល្អប្រាប់គ្រួសារ និង មិត្តភក្តិរបស់អ្នក ។

□ បង្រៀន (អ្នកអាចប្រើសៀវភៅនេះបាន) ពួកអ្នកជឿថ្មីឱ្យចេះមានទំនាក់ទំនង ពេញដោយសេចក្តីស្រឡាញ់កាន់តែខ្លាំងឡើងៗជាមួយនឹងគ្រួសារ និង មិត្តភក្តិរបស់គេ ហើយបង្រៀនអ្នកជឿថ្មីនោះ ឱ្យផ្សព្វផ្សាយដំណឹងល្អប្រាប់គ្រួសារ និងមិត្តភ័ក្តិទាំងនោះផង (គឺមិនមែនគ្រាន់តែអញ្ជើញពួកគេមកក្រុមជំនុំប៉ុណ្ណោះទេ តែត្រូវនិយាយប្រាប់ពួកគេអំពីព្រះអម្ចាស់យេស៊ូគ្រីស្ត នៅតាមផ្ទះរបស់ពួកគេផ្ទាល់ ដើម្បីអោយពួកគេកែប្រែចិត្តជឿលើព្រះគ្រីស្ត និង ទទួលពិធីជ្រមុជទឹក) ។





ការប្រឡង (សំនួរសង្ខេបមេរៀន)

យើងងាយនឹងនាំមិត្តភក្តិ និងសាច់ញាតិរបស់យើងអោយជឿលើព្រះជាម្ចាស់ ជាងមនុស្សដែលយើងមិនដែលស្គាល់ ។ ព្រោះអ្វី?

_____

_____

_____

_____

ក្រុមជំនុំមួយដែលមានត្រួសារទាំងមូលថ្វាយខ្លួនច្រើន ជាក្រុមជំនុំដែលរឹងមាំ ។ ព្រោះអ្វី ?

_____

_____

_____

_____

នៅពេលដែលអ្នកណាម្នាក់ទទួលព្រះគ្រីស្តហើយ សូមជួយគេឱ្យអាចផ្សព្វផ្សាយដំណឹងល្អប្រាប់គ្រួសារ និងមិត្តភក្តិរបស់គេផ្ទាល់ផង (កិច្ចការ ១៦:៣០-៣៤, យ៉ូហាន ៤:៣៤-៤២) ។

☐ បានអានរួចហើយ ។

លោកពេត្រុសបានផ្សព្វផ្សាយដំណឹងល្អ នៅក្នុងផ្ទះលោកគ័រនេល្យូស ហើយអស់អ្នកដែលនៅទីនោះក៏បានទទួលជឿព្រះគ្រីស្ត (កិច្ចការ ១០:៤៤) ។ ចំណុចអាថិកំបាំងដែលនាំអោយមានផលផ្លែដូចនេះ គឺ លោកគ័រនេល្យូសបានអញ្ជើញតែសាច់ញាតិ និងមិត្តភក្តិរបស់គាត់ប៉ុណ្ណោះ (កិច្ចការ ១០:២៤) ។

☐ បានអានរួចហើយ ។

សូមអាន និងពិចារណាពីគំរូនៃការផ្សាយដំណឹងល្អនៅក្នុងយ៉ូហាន ១:៤០-៥១ ។

☐ បានអានរួចហើយ ។

ដំបូងបង្អស់ យើងត្រូវផ្សព្វផ្សាយដំណឹងល្អ ដល់សាច់ញាតិ និង មិត្តភក្តិរបស់យើងជាមុនសិន

តាមធម្មតា ក្រុមជំនុំរីកចំរើនឡើងដោយសារមិត្តភក្តិ និងសាច់ញាតិរបស់យើងបានថ្វាយខ្លួន ។ មិត្តភក្តិ និងសាច់ញាតិយើងទុកចិត្តយើងជាងមនុស្សដែលគេមិនដែលស្គាល់ ។ ឧទាហរណ៍ : អ្នកជឿថ្មីម្នាក់នាំប្អូនប្រុស និងឪពុករបស់ខ្លួនឱ្យជឿលើព្រះគ្រីស្ត ហើយអ្នកដែលទើបនឹងថ្វាយខ្លួនទាំងអស់នោះ ក៏អាចនាំសាច់ញាតិ និងមិត្តភក្តិរបស់គេអោយជឿលើព្រះគ្រីស្តភ្លាមៗបានដែរ ។ ម្នាក់ៗត្រូវផ្សព្វផ្សាយដំណឹងល្អប្រាប់អ្នក ដែលជិតស្និទ្ធនឹងខ្លួនជាងគេ ។ ចលនាផ្សព្វផ្សាយដំណឹងល្អនេះ ចេះតែរីកចំរើនក្នុងចំណោមក្រុមគ្រួសារ និងមិត្តភក្តិ រហូតដល់ដំណឹងល្អសាយភាយពាសពេញសហគមន៍ទាំងមូល :



ឆ្លើយតបចំពោះដំណឹងល្អ ឬពួកគេរស់នៅឆ្ងាយពេក ។ ប៉ុន្តែ យើងអាចជួយអ្នកថ្វាយខ្លួននោះ ឱ្យមានក្រុមគ្រួសារខាងព្រលឹងវិញ្ញាណ គឺអោយគាត់ចាត់ទុកគ្រីស្តជនឯទៀត ជាក្រុមគ្រួសារគាត់វិញ ។ ចំណងដែលបង្រួបបង្រួមយើងក្នុងព្រះគ្រីស្ត អាចខ្លាំងជាងចំណងសាច់សារលោហិតទៅទៀត ។

តើនៅក្នុងរយៈពេលមួយអាទិត្យនេះ អ្នកឧស្សាហ៍និយាយជាមួយអ្នកណាខ្លះ ? ពួកអ្នកទាំងនោះហើយ ដែលព្រះជាម្ចាស់ចង់ឱ្យអ្នកផ្សព្វផ្សាយដំណឹងល្អប្រាប់មុនគេ ។ សូមសរសេរឈ្មោះសាច់-ញាតិ និងមិត្តភក្តិខ្លះ ដែលអ្នកអាចផ្សាយដំណឹងល្អដល់គេបាន :

បើសិនជាអ្នកជឿថ្មី មិនទាន់បាននិយាយប្រាប់អំពីជំនឿថ្មីរបស់ខ្លួន ដល់សមាជិកក្រុមគ្រួសារ និងមិត្តភក្តិរបស់គេទេ នោះគេពិបាកដើរតាមព្រះយេស៊ូដោយសុទ្ធចិត្តណាស់ ។ បើគេលាក់ គេនឹងមានការស្ទាក់ស្ទើរក្នុងការបំរើព្រះអង្គ ។ យើងត្រូវជួយអ្នកនោះឱ្យអាចចែកចាយពីជំនឿរបស់គាត់ដល់គ្រួសារគាត់បាន ។ យើងអាចទៅជាមួយគាត់ និងលើកទឹកចិត្តគាត់ក៏បានដែរ ។ ព្រះ-វិញ្ញាណដ៏វិសុទ្ធនឹងពង្រឹងជំនឿរបស់គាត់ នៅពេលដែលគាត់ហ៊ានប្រកាសជំនឿរបស់គាត់ នៅចំពោះមុខក្រុមគ្រួសាររបស់គាត់ (រ៉ូម ១០:៩-១០) ។ បន្ទាប់មក នឹងមានការងាយស្រួលក្នុងការដឹកនាំក្រុមគ្រួសាររបស់គាត់អោយថ្វាយខ្លួនដល់ព្រះគ្រីស្ត ។

នៅពេលដែលគ្រួសារទាំងមូលថ្វាយខ្លួន សមាជិកទាំងអស់អាចលើកទឹកចិត្តគ្នាទៅវិញទៅមក ។ ហេតុនេះហើយបានជាក្រុមជំនុំដែលមានក្រុមគ្រួសារទាំងមូលជាច្រើនថ្វាយខ្លួន រឹងមាំជាងក្រុមជំនុំដែលមានតែអ្នកជឿតែម្នាក់ឯង ដាច់ចេញពីក្រុមគ្រួសារ ថ្វាយខ្លួន ។ បើសមាជិកម្នាក់របស់គ្រួសារថ្វាយខ្លួនជឿតែម្នាក់ឯង ហើយគ្រួសារទាំងមូលមិនបានថ្វាយខ្លួន នោះអាចនាំអោយមានបញ្ហាធ្ងន់ធ្ងររវាងសមាជិកនោះនឹងគ្រួសារ ។ ពេលខ្លះ យើងមិនអាចដោះស្រាយបញ្ហាទាំងនេះបានទេ ពីព្រោះក្រុមគ្រួសារមិន

បើយើងចេះផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយសេចក្តីស្រឡាញ់ នោះយើងនឹងផ្សព្វផ្សាយដំណឹងល្អ បានប្រកបដោយប្រសិទ្ធិភាព : រ៉ូម ១:១៦, ១០:១៧, ១ កូរិនថូស ១៣:១ ។

☐ សូមគូសសញ្ញា «✓» ក្នុងប្រអប់ «☐» នេះ ពេលដែលអ្នកបានអានខគម្ពីរទាំងបីនេះហើយ ។



ក្រុមជំនុំនឹងរីកចំរើនឡើងបាន ដោយសារអ្នកជឿចែកចាយដំណឹងល្អក្នុងចំណោមមនុស្ស ដែលគេមានទំនាក់ទំនងពេញដោយសេចក្តីស្រឡាញ់រួចមកហើយ ។ ឧទាហរណ៍ ដូចជាក្នុងចំណោមបងប្អូន សាច់ញាតិ និងមិត្តភក្តិទាំងអស់របស់គេ (ទំនាក់ទំនងនេះ ប្រៀបដូចជាផ្លូវដែកមួយ) ។

ដើម្បីអោយចម្រូតបានផលល្អ យើងត្រូវខិតខំផ្សព្វផ្សាយដំណឹងល្អ ទៅមិត្តភក្តិ និង សាច់ញាតិដែលបានបើកចិត្តចង់ស្តាប់ដំណឹងល្អ ។ សូមកុំបង្ខាតពេលវេលារបស់អ្នកច្រើនពេកជាមួយពួកអ្នក ដែលមិនចាប់អារម្មណ៍ពីដំណឹងល្អ ។



នាំក្រុមគ្រួសារទាំងមូលអោយថ្វាយខ្លួន ទៅព្រះជាម្ចាស់ព្រមគ្នា

ជួនកាល យើងផ្សព្វផ្សាយដំណឹងល្អទៅមនុស្សម្នាក់ ដែលចាប់អារម្មណ៍លើដំណឹងល្អមែនទែន តែមិនចង់ថ្វាយខ្លួនទៅព្រះជា-ម្ចាស់ ។ ហេតុអ្វីបានជាគាត់មិនចង់ថ្វាយខ្លួន ? ជាទូទៅពីព្រោះតែក្រុមគ្រួសារ និងមិត្តភក្តិរបស់គាត់ ។

